**មាត្រា ២០.-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ។

**មាត្រា ២១.-**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០

ព្រះហស្តលេខា

នរោត្តម សីហនុ

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**

**សូមឡាយព្រះហស្តលេខា**

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូនសម្តេច

នាយករដ្ឋមន្ត្រី សូមចុះហត្ថលេខា

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង យូ ហុកគ្រី

***

**ព្រះរាជក្រឹត្យ នស/រកត/០៤០០/០៧៦**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិក មហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការ បង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

មាត្រា ១ .- បង្កើតក្រុមប្រឹក្សាកំណែទំរង់ប្រពន្ធ័យុត្តិធម៌មួយ សំរាប់ជាជំនួយការក្នុងកិច្ចប្រតិបត្តិបេសកកម្មរបស់ឧត្តម ក្រុមប្រឹក្សាកំណែទំរង់រដ្ឋលើវិស័យយុត្តិធម៌ហើយដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម ឌិត មុន្ទី | ប្រធានតុលាការកំពូល | ជាប្រធាន |
| ២-ឯកឧត្តម អ៊ុក វិធុន | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៣-លោកជំទាវ លី វុចឡេង | ប្រធានគណៈឧទ្ធរណ៍ | ជាអគ្គលេខាធិការ |
| ៤-ឯកឧត្តម ស៊ុយ នូ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៥-ឯកឧត្តម ឡើល មុន | សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ជាសមាជិក |
| ៦-ឯកឧត្តម ឡេង ប៉េងឡុង | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | ជាសមាជិក |
| ៧-ឯកឧត្តម ត្រាញ់ ជ័យណារិទ្ធិ | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃរាជរដ្ឋាភិបាល | ជាសមាជិក |

មាត្រា ២ .- ក្រុមប្រឹក្សាកំណែទំរង់ប្រពន្ធ័យុត្តិធម៌មានទីតាំងស្ថិតនៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៣ .- ក្រុមប្រឹក្សាកំណែទំរង់ប្រពន្ធ័យុត្តិធម៌មានបេសកកម្ម ផ្តួចផ្តើមជំរុញដាក់អោយដំណើរការនិងតាមដានការអនុវត្តន៍នយោបាយ និងកម្មវិធីកំណែទំរង់ប្រពន្ធ័យុត្តិធម៌ ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋជាពិសេសពង្រឹងប្រពន្ធ័តុលាការជាតិ ។

មាត្រា ៤ .- សមាជិកនៃក្រុមប្រឹក្សាកំណែទំរង់ប្រពន្ធ័យុត្តិធម៌ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៥ .- ការរៀបចំនិង ការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាកំណែទំរង់ប្រពន្ធ័យុត្តិធម៌ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៦ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាម ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ១៣៨ អនក្រ.គត

### ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា